U.S.-Asia PARTNERSHIPS FOR Environmental Law AT VERMONT LAW SCHOOL

# តួនាទីតុលាការនិងសាលាក្តីបរិស្ថាន បទពិសោធន៍អន្តរជាតិនិងមេរៀនទទួលបាន

ដោយលោក Matthew Baird
អ្នកសិក្សាស្រាវជ្រាវ នៃសាលាច្បាប់វែម៉ុង (Vermont Law School)



# ហេតុអ្វីត្រូវបង្កើតតុលាការនិងសាលាក្តីបរិស្ថាន (ECTs)?

- សេចក្តីប្រកាសស្តីពីបរិស្ថាន ទីក្រុងរីយ៉ូឆ្នាំ១៩៩២ បានបញ្ជាក់ឡើងវិញទៅលើសេចក្តីប្រកាសស្តីពីបរិស្ថានមនុស្ស ក្រុងស្តុកខមឆ្នាំ១៩៧២ និងបញ្ជាក់ឡើងវិញថា "ការការពារបរិស្ថាន ត្រូវបង្កើតជាចំណែកស្នូលមួយនៃដំណើរការអភិវឌ្ឍន៍និងមិនអាចយកមកពិចារណាដាច់ដោយឡែកឡើយ"
- គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពទី១៦ - "ផ្តល់ការទទួលបានយុត្តិធម៌សម្រាប់ទាំងអស់គ្នា និងកសាងស្ថាប័នប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងបរិយាប័ន្ន"។

# ហេតុអ្វីត្រូវបង្កើតតុលាការនិងសាលាក្ដីបរិស្ថាន (ECTs)?

- ការបំពុលបរិស្ថាន បម្រែបម្រួលអាកាសធាតុ និងការបង្កការខូចខាតដល់ប្រព័ន្ធអេកូឡូស៊ី ដោយរួមទាំង ការបាត់បង់ជីវសាស្ត្រចម្រុះ គឺជាបញ្ហាប្រឈមបំផុតនៅក្នុងសតវត្សនេះ
- ត្រូវការថៅក្រមដែលមានចំណេះដឹងនិងការបណ្ដុះបណ្ដាលពិសេស ក្នុងការលើកកម្ពស់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព
- អន្តរកម្មរវាងច្បាប់បរិស្ថាននិងច្បាប់រដ្ឋបាល ច្បាប់រដ្ឋប្បវេណីនិងច្បាប់ព្រហ្មទណ្ឌ
- ត្រូវការដំណោះស្រាយបណ្ដោះអាសន្នឬការរក្សាការពារ មានសារសំខាន់ណាស់ក្នុងសំណុំរឿងបរិស្ថាន

# រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា

## មាត្រា៥៩៖

រដ្ឋត្រូវរក្សាបរិស្ថាននិងតុល្យភាព នៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឲ្យមានផែនការច្បាស់លាស់ ក្នុងការគ្រប់គ្រង មានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពលប្រេងកាត និងឧស្ម័ន ថ្មនិងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល។

## មាត្រា៧០៖

បទល្មើសទាំងឡាយដែលប៉ះពាល់ ឬ ទាក់ទងនឹងបេតិកភណ្ឌវប្បធម៌សិល្បៈ ត្រូវផ្តន្ទាទោសជាទម្ងន់។

# ធម្មនុញ្ញអាស៊ាន - ខែធ្នូ ២០០៨

- ធម្មនុញ្ញអាស៊ាន មានបញ្ចូលគោលបំណងមួយក្នុងចំណោមគោលបំណងជាច្រើនគឺ៖
  – លើកកម្ពស់ **ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព** ដើម្បីធានាឲ្យមានការការពារបរិស្ថានតំបន់, **និរន្តរភាពធនធានធម្មជាតិ**, ការអភិរក្សបេតិកភណ្ឌវប្បធម៌ និងគុណភាពខ្ពស់សម្រាប់ជីវិតមនុស្ស។

ធម្មនុញ្ញអាស៊ាន មាត្រា 1(9)

# តើអ្វីជាការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព?

បញ្ញត្តិដើមនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដែលបានផ្សព្វផ្សាយនៅក្នុង *អនាគតរួមរបស់យើង* គឺជា "ការអភិវឌ្ឍន៍ដែលបំពេញបានតាមតម្រូវការនាពេលបច្ចុប្បន្ន ដោយមិនត្រូវប៉ះពាល់ដល់អនាគតរបស់ជំនាន់ផ្សេងទៀត ក្នុងការបំពេញតម្រូវការរបស់ពួកគេឡើយ"។



WCED, 1987.

- *ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព* គឺជា "ការអភិវឌ្ឍន៍ដែលកែលម្អគុណភាពជីវិតទាំងស្រុង ទាំងក្នុងពេលបច្ចុប្បន្ននិងក្នុងពេលអនាគត តាមវិធីដែលរក្សាដំណើរការប្រព័ន្ធអេកូឡូស៊ីដែលជីវិតត្រូវពឹងផ្អែកទៅលើ"។

# ផលវិបាកដែលកើតចេញមកពីការខកខាន មិនបានការពារបរិស្ថាន – PRC



# បញ្ហាបរិស្ថាន

- ការបង្កការខូចខាតដល់បរិស្ថាន (ដោយរាប់បញ្ចូលទាំងទៅលើសុខភាពមនុស្សនិងសត្វ) អាចមានការលំបាកក្នុងការបញ្ជាក់បង្ហាញ
- គេត្រូវការភស្តុតាង ដោយរាប់ទាំងភស្តុតាងលក្ខណៈវិទ្យាសាស្ត្រ និងការភស្តុតាងនៃការបង្កឡើងនិងការទទួលខុសត្រូវដោយផ្ទាល់
- ការទទួលខុសត្រូវរបស់អង្គភាពច្បាប់ នាយក និងម្ចាស់


蜂鸟网
fengniao.com

# ទន្លេលក្ខក្រហម Jian River Luoyang










# តុលាការពិសេសផ្នែកបរិស្ថាន

- ជំនាញ ក្នុងការយល់ដឹងអំពីបញ្ហាបរិស្ថាន
- នីតិវិធីពិសេស ក្នុងការដោះស្រាយសំណុំរឿងបរិស្ថាន
  - 90% គួរដោះស្រាយក្នុងរយៈពេល ២ឆ្នាំ
- ការដាក់ទណ្ឌកម្មអាចត្រឹមត្រូវតាមបទល្មើស៖
  - ការពិន័យ – ការដាក់ពន្ធនាគារ – ទោសប្បញ្ញត្តិប្រចាំឆ្នាំ
  - ការជូនដំណឹងអំពីការបោះពុម្ពផ្សាយ
  - យុត្តិធម៌ស្តារឡើងវិញ – ការជូនដំណឹងអំពីការសម្អាត
  - សំណងសម្រាប់ការបង្កការខូចខាត
  - ការចំណាយទៅលើការការស៊ើបអង្កេត/ការកាត់ទោស

# តុលាការពិសេសផ្នែកបរិស្ថាន

- ក្នុងឆ្នាំ២០១៦ មានតុលាការនិងសាលាក្តីផ្នែកបរិស្ថានចំនួន ១២០០ ក្នុងប្រទេសចំនួន ៤៤ នៅថ្នាក់ជាតិឬថ្នាក់រដ្ឋ/ខេត្ត និងមានប្រទេសប្រហែលជា២០ទៀត កំពុងពិភាក្សាឬធ្វើផែនការបង្កើតតុលាការនិងសាលាក្តីផ្នែកបរិស្ថាន។
- មានគម្រូជាច្រើនផ្សេងៗគ្នាអំពីតុលាការនិងសាលាក្តីផ្នែកបរិស្ថាននៅជុំវិញពិភពលោក។ តុលាការនិងសាលាក្តីផ្នែកបរិស្ថាន អាចជាតុលាការ (សាខាក្នុងប្រព័ន្ធយុត្តិធម៌) ឬជាសាលាក្តី (សាខាក្នុងនីតិប្រតិបត្តិឬក្រសួង)

| | | | |
|---|---|---|---|
| កម្ពុជា | សភាបរិស្ថាន | | |
| ថៃ | នាយកដ្ឋានបរិស្ថាននៅគ្រប់កម្រិត (សរុប២១) ទាំងតុលាការកំពូលនិងតុលាការរដ្ឋបាលកំពូល | បណ្តុះបណ្តាលចៅក្រោមក្នុងប្រទេសអូស្ត្រាលី | នីតិវិធីពិសេសសម្រាប់សំណុំរឿង បរិស្ថាន ២០១០ |
| ម៉ាឡេស៊ី | តុលាការបរិស្ថាន បង្កើតឡើងតុលាការកម្រិតសហព័ន្ធនិងកម្រិតរដ្ឋមួយចំនួន | ការបណ្តុះបណ្តាលផ្តល់សម្រាប់ចៅក្រមបៃតង | តុលាករដាន់ទាប៩៥ សម្រាប់បទល្មើសបរិស្ថាន |
| ឥណ្ឌូណេស៊ី | មិនមានការបង្កើតតុលាការបរិស្ថានទេ។ ក្រុមចៅក្រោមបានធ្វើការបណ្តុះបណ្តាលចៅក្រមផ្នែកបរិស្ថាន | ការបណ្តុះបណ្តាលនិងការផ្តល់វិញ្ញាបនប័ត្រដល់ចៅក្រមបរិស្ថានតាំងពីឆ្នាំ១៩៩២ | តុលាការព្រៃឈើ និងតុលាការជលផល ដោះស្រាយបញ្ហាទាំងនេះ |
| មីយ៉ាន់ម៉ា | គ្មាន | | ចែងនៅក្នុងសេចក្តីព្រាងគោលនយោបាយបរិស្ថាន ២០១៧ |

| | | | |
|---|---|---|---|
| ហ្វីលីពីន | តុលាការពិសេសបង្កើតឡើងក្នុងឆ្នាំ ២០០៨។ តុលាការកំពូលបានចាប់យកយុត្តាធិការមួយចំនួនសម្រាប់សំណុំរឿងសំខាន់ៗ | ចៅក្រមទាំងអស់ជាមេធាវីដែលបានទទួលការបណ្តុះបណ្តាល | តុលាការថ្នាក់តំបន់និងថ្នាក់ក្រុងចំនួន១១៧។ វិធានពិសេសសម្រាប់តុលាការកំពូលក្នុងសំណុំរឿងបរិស្ថាន។ នីតិវិធីពិសេស ២០១០។ |
| ឥណ្ឌា | សាលាក្តីបៃតងថ្នាក់ជាតិ(2010) | ចៅក្រមត្រូវបានតែងតាំងដោយរដ្ឋាភិបាលថ្នាក់ជាតិ | មុខងារជាតុលាការរដ្ឋប្បវេណី។ យុត្តាធិការមានកំណត់ត្រឹមតែច្បាប់បរិស្ថានចម្បងៗចំនួន៧ ប៉ុណ្ណោះ |
| ប៉ាគីស្ថាន | តុលាការជំនុំជម្រះនិងជាន់ខ្ពស់ចំនួន២៥០ត្រូវបានបង្កើតឡើងជាអង្គចៅក្រមបៃតង | ប្រធានចៅក្រមប្រចាំខេត្តចាត់តាំងចៅក្រម | |
| បង់ក្លាដេស | តុលាការបរិស្ថានចំនួន៣ និងសាលាឧទ្ធរណ៍ថ្នាក់ជាតិ១ | | |

# តុលាការពិសេសផ្នែកបរិស្ថាន

- របាយការណ៍ UNEP 2016 កំណត់រកឃើញបញ្ហាសំខាន់ៗមួយចំនួន សម្រាប់ធ្វើឲ្យ តុលាការនិងសាលាក្តីផ្នែកបរិស្ថាន មានប្រសិទ្ធភាព
  – កង្វះខាតចំណេះដឹង របស់ចៅក្រមនិងសមាជិកច្បាប់បរិស្ថានជាតិនិងច្បាប់បរិស្ថានជាតិ
  – ការពន្យារនីតិវិធិរបស់តុលាការនិងសាលាក្តីផ្នែកបរិស្ថាន និងការកំណត់អំពីសំណុំរឿងបរិស្ថាន
  – ការចំណាយខ្ពស់សម្រាប់ភាគីនៅចំពោះមុខតុលាការនិងសាលាក្តីផ្នែកបរិស្ថាន
  – កង្វះការកំណត់ជាអាទិភាពទៅលើសំណុំរឿងបរិស្ថាន
  – ដំណោះស្រាយមិនគ្រប់គ្រាន់
  – វិធីសាស្ត្រយកឈ្នះចាញ់
  – វិធាននិងនីតិវិធីមិនមានភាពបត់បែន សម្រាប់សំណុំរឿងបរិស្ថាន

# តុលាការពិសេសផ្នែកបរិស្ថាន

- 2016 UNEP Report recommends that can be designed to:
  - promote the environmental rule of law at the national level and international levels and ensure equal access to justice (SDG target 16.3)
  - develop more effective, accountable and transparent institutions at all levels (SDG target 16.6)
  - ensure responsive, inclusive, participatory and representative decision-making at all levels (SDG target 16.7)
  - ensure public access to information and protect fundamental freedoms, in accordance
  - with national legislation and international agreements (SDG target 16.10) and
  - especially promote and enforce non-discriminatory laws and policies for sustainable development (SDG target 16.b).

# តុលាការពិសេសផ្នែកបរិស្ថាន

ថៅក្រម Lynch និង Stein របស់ EAB បានកំណត់រកឃើញកត្តានានា ដើម្បីជោគជ័យរបស់តុលាការនិងសាលាក្ដីផ្នែកបរិស្ថាន។ កត្តាទាំងនេះ មានរួម (តែមិនទាន់អស់នៅឡើយ)៖

- ចៅក្រុមវិជ្ជាជីវៈ ដែលយល់ដឹងអំពីច្បាប់និងវិទ្យាសាស្ត្របរិស្ថាន
- ការហាមឃាត់ទៅលើការទាក់ទងភាគីតែម្ខាង និងទំនាស់ផលប្រយោជន៍
- វិធានសរសេរច្បាស់ជាលាយលក្ខណ៍អក្សរ
- សំណុំរឿងនិងការសម្រេចចិត្តទាំងអស់ ត្រូវដាក់ឲ្យរកបានជាសាធារណៈតាមប្រព័ន្ធអ៊ីនធឺណែត
- ភាពអាចរកបាន មជ្ឈតកម្ម តាមសំណូមពរ
- ការបណ្ដុះបណ្ដាលនិងការផ្លាស់ប្ដូរកិច្ចសហប្រតិបត្តិការ

# តុលាការពិសេសផ្នែកបរិស្ថាន

Preston CJ តុលាការផ្នែកដីធ្លីនិងបរិស្ថាននៅ NSW បានកំណត់រកឃើញលក្ខណៈចំនួន១២ នៃតុលាការនិងសាលាក្ដីផ្នែកបរិស្ថានជោគជ័យ៖

- ឋានៈនិងអាជ្ញាធរ
- ឯករាជ្យភាពពីរដ្ឋាភិបាលនិងមិនលម្អៀង
- យុត្តាធិការទូលំទូលាយនិងមជ្ឈការ
- ចៅក្រមនិងសមាជិក មានចំណេះដឹងនិងមានសមត្ថកិច្ច
- ប្រតិបត្តិការក្នុងនាមជាតុលាការដែលមានឯកទេសចម្រុះ
- ផ្ដល់ឲ្យមានការទទួលបានជំនាញលក្ខណៈវិទ្យាសាស្ត្រនិងបច្ចេកទេស

# តុលាការពិសេសផ្នែកបរិស្ថាន

- សម្រួលដល់ការទទួលបានយុត្តិធម៌
- សម្រេចបាននូវដំណោះស្រាយវិវាទដែលមានយុត្តិធម៌ រហ័ស និងមិនថ្លៃ
- ដែលឆ្លើយតបទៅនឹងបញ្ហាបរិស្ថាននិងមានការជាប់ទាក់ទង
- បង្កើតករណីយុត្តិសាស្ត្រលើករណីបរិស្ថាន
- បញ្ជាក់អំពីសេចក្តីប្រាថ្នានិងបេសកកម្ម
- មុខងារដែលមានភាពបត់បែន ច្នៃប្រឌិត និងផ្តល់គុណតម្លៃបន្ថែម

# អាជ្ញាធរអយ្យការលើបញ្ហាបរិស្ថាន

- ឯករាជ្យ
  - រៀបចំសំណុំរឿង ដោយយោងតាមសេចក្តីណែនាំក្នុងការចោទប្រកាន់
  - ផ្តោតទៅលើសំណុំរឿងចម្បងៗសម្រាប់ការជំនុំជម្រះ
    - សាជីវកម្ម
    - នាយកក្រុមហ៊ុន
  - ទណ្ឌកម្មផ្នែករដ្ឋបាលសម្រាប់ករណីតូចៗ
  - មានធនធានគ្រប់គ្រាន់ក្នុងការជួយដល់ផ្នែកវិទ្យាសាស្ត្រ សម្រាប់ការធ្វើតេស្ត៏និងការបញ្ជាក់អំពីមូលហេតុបណ្តាល និងការបង្កការខូចខាត

**Matthew Baird**
Environmental Counsel
MEIANZ, Cert. Env. Pract.

+612 8003 4878
+668 4613 2340
matthewhbaird

**environmentalcounsel.asia**